# ធ្វើឲ្យការយល់ដឹងរបស់អ្នកអំពីសម្បថ និងសេចក្ដីសញ្ញានៃបព្វជិតភាពកាន់តែស៊ីជម្រៅ

### បានញែកជាបរិសុទ្ធដោយសារព្រះវិញ្ញាណ ចំពោះការសាងរូបកាយរបស់ពួកគេជាថ្មី ( សូមមើល ខទី ៣៣ )

នៅក្នុងការនិយាយអំពីការសន្យារបស់ព្រះវរបិតាសួគ៌ ប្រធាន ហិនរី ប៊ី អាវរិង នៃគណៈប្រធានទីមួយបានពន្យល់ថា ៖



ខ្ញុំបានឃើញការសន្យានោះត្រូវបានបំពេញ នៅក្នុងជីវិតរបស់ខ្ញុំផ្ទាល់ និងនៅក្នុងជីវិតរបស់អ្នកដទៃទៀត ។ មិត្តរបស់ខ្ញុំម្នាក់ បានបម្រើជាប្រធានបេសកកម្ម ។ គាត់បានប្រាប់ខ្ញុំថា នៅចុងបញ្ចប់នៃថ្ងៃនីមួយៗ ខណៈគាត់កំពុងបម្រើ គាត់ស្ទើរតែមិនអាចឡើងជណ្ដើរទៅជាន់ខាងលើដើម្បីទៅគេងនៅពេលយប់បាន ដោយមិនបានគិតថា បើគាត់នឹងមានកម្លាំងដើម្បីប្រឈមនឹងថ្ងៃស្អែកដែរឬទេ ។ ហើយនៅព្រឹកឡើង គាត់នឹងបានឃើញថា កម្លាំងរបស់គាត់ ហើយនិងសេចក្ដីក្លាហានរបស់គាត់ត្រូវបានស្ដារឡើងវិញ ។ អ្នកបានឃើញវានៅក្នុងជីវិតរបស់ពួកព្យាការីដែលមានអាយុច្រើន ដែលហាក់ដូចជាត្រូវបានសាងឡើងជាថ្មី នៅរាល់ដងដែលពួកលោកបានឈរថ្លែងទីបន្ទាល់អំពីព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ និងដំណឹងល្អដែលបានស្ដារឡើងវិញ ។ នោះគឺជាការសន្យាមួយសម្រាប់ពួកអ្នកទាំងឡាយណា ដែលឈានឆ្ពោះទៅមុខដោយសេចក្ដីជំនឿក្នុងការបម្រើបព្វជិតភាពរបស់ពួកគេ ។ ( ហិនរី ប៊ី អាវរិង « Faith and the Oath and Covenant of the Priesthood » *Liahona* ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៦២ )

### ចូរស្មោះត្រង់ក្នុងកាលបានបព្វជិតភាពអើរ៉ុន និងមិុលគីស្សាដែក ( សូមមើល ខទី ៣៣ )

ដើម្បីស្មោះត្រង់ « ស្មោះត្រង់ក្នុងកាលបានបព្វជិតភាពទាំងពីរនេះ » ( គោលលទ្ធិ និងសេចក្ដីសញ្ញា ៨៤:៣៣ ) ទាក់ទងនឹងកាលបានអំណាច និងពរជ័យដែលកើតចេញពីការទទួលពិធីបរិសុទ្ធនៃបព្វជិតភាពអើរ៉ុន និងមិុលគីស្សាដែក និងការគោរពតាមសេចក្ដីសញ្ញាដែលទាក់ទងដោយស្មោះត្រង់ ។ ព្យាការី យ៉ូសែប ស្ម៊ីធ បានបង្រៀនថា មនុស្សម្នាក់ទទួលបានភាពពេញលេញនៃបព្វជិតភាព « ដោយការកាន់តាមបទបញ្ញត្តិទាំងអស់ ហើយប្រតិបត្តិតាមគ្រប់ពិធីបរិសុទ្ធនៃដំណាក់របស់ព្រះអម្ចាស់ » ( Teachings of Presidents of the Church: Joseph Smith [ ឆ្នាំ ២០០៧ ] ទំព័រ ៤១៩ ) ។

សម្រាប់បុរស នេះក៏រួមបញ្ចូលទាំងការប្រគល់បព្វជិតភាពដល់ពួកគេ និងត្រូវបានតែងតាំងឲ្យកាន់តំណែងបព្វជិតភាពផងដែរ ។

### តម្កើងការហៅរបស់អ្នក ( ខទី ៣៣ )

គោលលទ្ធិ និងសេចក្ដីសញ្ញា ៥៨:២៧–២៨; ១០៧:៩៩–១០០

### ឱកាសដើម្បីទទួលការហៅ និងចូលរួមក្នុងកិច្ចការនៃសេចក្ដីសង្គ្រោះរបស់ព្រះអម្ចាស់

ប្រធាន អិម រ័សុល បាឡឹដ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀន ៖



នៅពេលយើងធ្វើការដើម្បីតម្កើងការហៅរបស់យើង យើងគួរតែស្វែងរកការបំផុសគំនិតពីព្រះវិញ្ញាណ ដើម្បីដោះស្រាយបញ្ហាតាមរបៀបដែលនឹងជួយមនុស្សដែលយើងបម្រើបានល្អបំផុត ។ យើងមានសៀវភៅក្បួនខ្នាត ហើយគោលការណ៍ការណែនាំរបស់វាគួរតែត្រូវបានធ្វើតាម ។ ប៉ុន្តែនៅក្នុងគោលគំនិតនោះ គឺជាឱកាសដ៏សំខាន់ក្នុងការគិត បង្កើតគំនិតច្នៃប្រឌិត និងប្រើប្រាស់ទេពកោសល្យផ្ទាល់ខ្លួន ។ ការណែនាំដើម្បីតម្កើងការហៅរបស់យើង មិនមែនជាពាក្យបញ្ជាដើម្បីលំអ និងធ្វើឲ្យវាស្មុគស្មាញនោះទេ ។ ការបង្កើតថ្មីមិនមានន័យថាពង្រីកនោះទេ ជាញឹកញាប់វាមានន័យថា ធ្វើឲ្យសាមញ្ញ ។ ( អិម រ័សុល បាឡឹត « O Be Wise » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៦ ទំព័រ ១៩ )

### អ្វីៗដែលព្រះវរបិតាសួគ៌មាន ( សូមមើល ខទី ៣៨ )

គោលលទ្ធិ និងសេចក្ដីសញ្ញា ៧៦:៥៥–៦០; ៨១:៦